

# ទិវា ជនជាតិដើមភាគតិច ពិភពលោក ឆ្នាំ២០២៣

បច្ចុប្បន្នភាពនៃការទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាពសម្រាប់សហគមន៍ជនជាតិដើមភាគតិចឆ្នាំ២០២៣

និងក្ដីកង្វល់





មានលិខិតបទដ្ឋានគតិយុត្តសំខាន់ចំនួន២ ដើម្បីធានានូវនីតិវិធីក្នុងការចុះបញ្ជី និងផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពជូនជនជាតិដើមភាគតិច គឺច្បាប់ភូមិបាលឆ្នាំ២០០១ និងអនុក្រឹត្យលេខ. ៨៣ ឆ្នាំ ២០០៩ ស្តីពីនីតិវិធីនៃការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច។

**គោលនយោបាយស្តីពីការចុះបញ្ជីដី និងសិទ្ធិប្រើប្រាស់ដីសហគមន៍ជនជាតិដើមភាគតិចនៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩។**

ចក្ខុវិស័យ និងគោលបំណង (កថាខណ្ឌ២) ៖
គោលដៅនៃការអភិវឌ្ឍជនជាតិដើមភាគតិច គឺការលើកកម្ពស់កម្រិតជីវភាពរស់នៅតាមរយៈកសិកម្ម ដែលជាផ្នែកមួយដ៏សំខាន់នៃមុខរបរចិញ្ចឹមជីវិតប្រចាំថ្ងៃរបស់ពួកគាត់។ ដូច្នេះ ការចុះបញ្ជីដីធ្លីជូនសហគមន៍ជនជាតិដើមភាគតិច ជាការធានានូវសុវត្ថិភាពនៃការកាន់កាប់ដីធ្លីដែលបង្កលទ្ធភាពឱ្យពួកគាត់ប្រើប្រាស់ដីកាន់តែមានលទ្ធភាពខ្ពស់។

**២០១១-២០១៧**
៤,១៤%
នៃ៤៥៨ សហគមន៍បានទទួលប័ណ្ណកម្មសិទ្ធិសមូហភាព

ការចុះបញ្ជីប័ណ្ណកម្មសិទ្ធិដីសមូហភាពដំបូងបានធ្វើឡើងក្នុងឆ្នាំ២០១១។ មកដល់ឆ្នាំ២០១៧ គឺមានសហគមន៍ចំនួន១៩ ស្មើ ៤,១៤% នៃសហគមន៍ជនជាតិដើមភាគតិចនៅកម្ពុជាចំនួន ៤៥៨ សហគមន៍ដែលបានទទួលប័ណ្ណកម្មសិទ្ធិសមូហភាព។

ក្នុងឆ្នាំ២០១៧ នោះដែរ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់បានប្រកាសពីការប្តេជ្ញាចិត្តជំរុញការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិចឱ្យបាន១០ សហគមន៍ក្នុង១ឆ្នាំ។

**២០១៧-២០២២**
៣៦%
នៃការប្តេជ្ញាចិត្តរបស់ក្រសួងសម្រេចបាន

រយៈពេល ៥ឆ្នាំ គឺចាប់ពីឆ្នាំ២០១៧ រហូតដល់ខែកក្កដា ឆ្នាំ២០២២ មានសហគមន៍តែចំនួន១៨ បន្ថែមទៀតស្មើ ៣៦% នៃការប្តេជ្ញាចិត្តរបស់ក្រសួងប៉ុណ្ណោះដែលបានទទួលប័ណ្ណកម្មសិទ្ធិដីកម្មសិទ្ធិសមូហភាព។

**២០២២-២០២៣**
៣០%
នៃការប្តេជ្ញាចិត្តរបស់ក្រសួងសម្រេចបាន

រយៈពេល ១១ខែ គឺចាប់ពីខែកក្កដា ឆ្នាំ២០២២ ដល់ខែមិថុនា ឆ្នាំ២០២៣ មានសហគមន៍ចំនួន ៣ បន្ថែមទៀត ស្មើ ៣០% នៃការប្តេជ្ញាចិត្តរបស់ក្រសួងបានទទួលប័ណ្ណកម្មសិទ្ធិដីសមូហភាព។

**២០១១-២០២៣**
៨,៧៣%នៃសហគមន៍ទទួលបានកម្មសិទ្ធិដីសមូហភាព

លទ្ធផលសរុបរយៈពេល១២ឆ្នាំ គឺចាប់ពីឆ្នាំ២០១១ រហូតដល់ខែមិថុនា ឆ្នាំ២០២៣ មានសហគមន៍ជនជាតិដើមភាគតិចចំនួន ៤០សហគមន៍ (រួមមានចំនួន ៣.៨៩៣ គ្រួសារ) ស្មើ ៨,៧៣% នៃសហគមន៍ជនជាតិភាគតិចសរុបចំនួន ៤៥៨ សហគមន៍ដែលបានទទួលប័ណ្ណកម្មសិទ្ធិដីសមូហភាព។

| ៤ ខេត្ត | ៤០ សហគមន៍ | ចំនួន ៤០.៧៣២,៤២ ហិកតា | ចំនួន ៣.៨៩៣ គ្រួសារ |
|---|---|---|---|
| រតនគិរី | ២៧ | ២៧.៨០០,២៥ | ២.៦៦៦ |
| មណ្ឌលគិរី | ៧ | ៦.១៥៥,៦៦ | ៤៧៣ |
| ក្រចេះ | ៤ | ៤.៧៨៤,៩៩ | ៦២៩ |
| ស្ទឹងត្រែង | ២ | ១.៩៩១,៥១ | ១២៥ |



## ក្តីកង្វល់

ក្តីកង្វល់សំខាន់មួយក្នុងចំណោមក្តីកង្វល់ដទៃទៀតរបស់សហគមន៍ជនជាតិដើមភាគតិច គឺការមិនដាក់បញ្ចូលពាក្យ«សហគមន៍ជនជាតិដើមភាគតិច» នៅក្នុងសេចក្តីព្រាងវិសោធនកម្មច្បាប់ស្តីពីតំបន់ការពារធម្មជាតិ និងច្បាប់ស្តីពីព្រៃឈើ តែជំនួសវិញដោយពាក្យ «សហគមន៍មូលដ្ឋាន»។

ការកំណត់ពាក្យសហគមន៍មូលដ្ឋាននៅក្នុងសេចក្តីព្រាងវិសោធនកម្មច្បាប់ទាំងពីរមិនអាចជំនួសឱ្យពាក្យសហគមន៍ជនជាតិដើមភាគតិចបានឡើយ។

សហគមន៍ជនជាតិដើមភាគតិច មានដើមកំណើត ជាតិពន្ធុ ភាសា សង្គម វប្បធម៌ផ្សេងពីគេ ជាពិសេស ការប្រតិបត្តិប្រកបមុខរបរចិញ្ចឹមជីវិតមានទំនាក់ទំនងផ្ទាល់ជាមួយដីធ្លី និងធនធានធម្មជាតិ រស់ទៅតាមប្រពៃណី និងដាំដុះលើដីដែលខ្លួនកាន់កាប់ តាមក្បួនខ្នាតទំនៀមទំលាប់នៃការប្រើប្រាស់ជាសមូហភាព។





សហគមន៍មូលដ្ឋាន ដូចជាសហគមន៍តំបន់ការពារធម្មជាតិ និងសហគមន៍ព្រៃឈើ មិនគ្របដណ្តប់ទៅលើទីកន្លែងដីប្រើប្រាស់អាស្រ័យផលតាមប្រពៃណី និងព្រៃជំនឿសាសនាទាំងអស់ដែលជនជាតិដើមភាគតិចធ្លាប់មានដាក់ស្តែងពីមុនមកនោះទេ។



ដូចនេះ សហគមន៍ជនជាតិដើមភាគតិចស្នើឱ្យបញ្ញត្តិ «បុគ្គលជនជាតិដើមភាគតិច និងសហគមន៍ជនជាតិដើមភាគតិច» នៅក្នុងបទប្បញ្ញត្តិវិសោធនកម្មច្បាប់ស្តីពីតំបន់ការពារធម្មជាតិ និងច្បាប់ស្តីពីព្រៃឈើ។



---

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាសូមលើកទឹកចិត្តដល់រាជរដ្ឋាភិបាលកម្ពុជា ពន្លឿនការចុះបញ្ជីប័ណ្ណកម្មសិទ្ធិដីសមូហភាពសម្រាប់ជនជាតិដើមភាគតិច ឆ្លើយតបនឹងការប្តេជ្ញាចិត្តរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ចាប់តាំងពីឆ្នាំ២០១៧ រហូតមកដល់បច្ចុប្បន្ន។ រាជរដ្ឋាភិបាលកម្ពុជាគួរពិចារណាលើសំណើរបស់សហគមន៍ជនជាតិដើមភាគតិចដោយបញ្ញត្តិ «បុគ្គលជនជាតិដើមភាគតិច និងសហគមន៍ជនជាតិដើមភាគតិច» នៅក្នុងបទប្បញ្ញត្តិវិសោធនកម្មច្បាប់ស្តីពីតំបន់ការពារធម្មជាតិ និងច្បាប់ស្តីពីព្រៃឈើ ដើម្បីរក្សាលក្ខខណ្ឌប្រពៃណីវប្បធម៌ សាសនា និងអត្តសញ្ញាណរបស់ជនជាតិដើមភាគតិច។


ប្រភព ៖

១. របាយការណ៍បូកសរុបលទ្ធផលនៃការអនុវត្តការងាររបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ខែមិថុនា ឆ្នាំ២០២៣។

២. របាយការណ៍មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា «ការចុះបញ្ជីដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិចនៅកម្ពុជា» ឆ្នាំ២០១៦។

៣. គោលនយោបាយស្តីពីការចុះបញ្ជីដី និងសិទ្ធិប្រើប្រាស់ដីសហគមន៍ជនជាតិដើមភាគតិចនៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩។

៤. សេចក្តីថ្លែងការណ៍រួមរបស់សហគមន៍ជនជាតិដើមភាគតិចនៃព្រះរាជាណាចក្រកម្ពុជា ស្តីពីលទ្ធផលប្រមូលធាតុចូលក្នុងសេចក្តីព្រាងវិសោធនកម្មច្បាប់ស្តីពីតំបន់ការពារធម្មជាតិ និងច្បាប់ស្តីពីព្រៃឈើ នៅសណ្ឋាគារសោមាទេវីអង្គរ រីសត ក្រុងសៀមរាប ថ្ងៃទី១៥-១៦ ខែសីហា ឆ្នាំ២០២២។


ខែសីហា ឆ្នាំ២០២៣



CC BY NC SA